# ជំងឺរលាកថ្លើមប្រភេទ B

## តើលោកអ្នកប្រឈមនឹងជំងឺនេះដែរឬទេ?

### តើជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺបែបណាដែរ?

ជំងឺរលាកថ្លើមប្រភេទ B គឺជាជំងឺថ្លើម បង្កឡើងដោយវីរុសជំងឺរលាកថ្លើមប្រភេទ B ។ ចំពោះមនុស្សមួយចំនួនដែលមានជំងឺរលាកថ្លើមប្រភេទ B មានវីរុសប្រភេទនេះនៅក្នុងខ្លួន ដែលធ្វើអោយមានជំងឺពេញមួយជីវិត ។ ជំងឺរលាកថ្លើមប្រភេទ B អាចបណ្តាលអោយមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរជាយថាហេតុ ។ បញ្ហាទាំងនេះ អាចជាជំងឺមហារីកថ្លើម និងការបាត់បង់សមត្ថភាពថ្លើមផងដែរ ។

### តើជំងឺរលាកថ្លើមប្រភេទ B អាចឆ្លងបានដោយរបៀបណាដែរ?

ជំងឺរលាកថ្លើមប្រភេទ B ឆ្លងបាន នៅពេលនរណាម្នាក់បានប៉ះនឹងឈាមរបស់ជនណាម្នាក់ដែលមានជំងឺនេះ ។ មនុស្សភាគច្រើនដែលបានកើតក្នុងប្រទេសកម្ពុជា និងប្រទេសអាស៊ីឯទៀត ដែលមានជំងឺរលាកថ្លើមប្រភេទ B គឺបានឆ្លងជំងឺនេះតាំងពីទារក ឬកុមារតូចមកម្ល៉េះ ។ ជំងឺរលាកថ្លើមប្រភេទ B អាចចម្លងពីម្តាយដែលមានជំងឺទៅទារកពីកំណើត ឬពីសមាជិកគ្រួសារទៅកុមារតូចៗ ។

ជំងឺរលាកថ្លើមប្រភេទ B គឺពុំមែនជាជំងឺតពូជនោះទេ ។ មនុស្សក៏មិនអាចកើតជំងឺរលាកថ្លើមប្រភេទ B ពីការបរិភោគអាហារ និងការប្រើប្រាស់ចានក្បាន ឬសម្ភារៈប្រើប្រាស់ ជាមួយអ្នកមានជំងឺឡើយ ។ ជំងឺរលាកថ្លើមប្រភេទ B មិនឆ្លងតាមការបៅដោះ ការអោបការថើប ការកាន់ដៃ ការក្អក ឬ ការកណ្តាស់នោះឡើយ ។

### តើជំងឺរលាកថ្លើមប្រភេទ B មានកម្រិតច្រើនប៉ុណ្ណាដែរ?

ជំងឺរលាកថ្លើមប្រភេទ B កើតមានជាទូទៅ នៅក្នុងប្រទេសកម្ពុជា និងប្រទេសអាស៊ីឯទៀត ។ មានជនជាតិអាស៊ីប្រមាណ 1 នាក់ ក្នុង 12 នាក់ កំពុងតែរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B ប៉ុន្តែមនុស្សភាគច្រើនមិនដឹងថាខ្លួនមានជំងឺនេះឡើយ ។

### តើជំងឺរលាកថ្លើមប្រភេទ B មានសញ្ញារោគអ្វីខ្លះ?

មនុស្សភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ B មិនដឹងថាខ្លួនមានជំងឺនោះទេ ។ ជំងឺនេះមិនតែងតែបង្ហាញចេញជារោគសញ្ញានោះទេ ។ ជំងឺរលាកថ្លើមប្រភេទ B អាចសំងំនៅក្នុងខ្លួន ។ មានមនុស្សជាច្រើនអាចរស់នៅជាមួយជំងឺរលាកថ្លើមប្រភេទ B បានដល់រយៈពេល 20 ឆ្នាំ ដោយមិនធ្លាក់ខ្លួនឈឺឡើយ ។ ប៉ុន្តែ ការខូចថ្លើមដោយសារជំងឺនេះ អាចកើតឡើងក្នុងអំឡុងពេលនោះដែរ ។

### តើជំងឺរលាកថ្លើមប្រភេទ B មានកម្រិតធ្ងន់ធ្ងរយ៉ាងណាដែរ?

ជំងឺរលាកថ្លើមប្រភេទ B អាចក្លាយទៅជាធ្ងន់ធ្ងរយ៉ាងធំ ។ ចំពោះអ្នកខ្លះទៀត ជំងឺនេះនាំទៅការខូចថ្លើម ដូចជាការបាត់បង់សមត្ថភាពថ្លើម ឬជំងឺមហារីកថ្លើម ។

### តើមនុស្សដឹងថាពួកគេមានជំងឺរលាកថ្លើមប្រភេទ B បានដោយរបៀបណាដែរ ?

តេស្តជំងឺរលាកថ្លើមប្រភេទ B ប្រាប់ពួកគេអោយដឹងបានថាមានជំងឺនេះនៅក្នុងខ្លួនរបស់គេ ឬយ៉ាងណានោះ ។ តេស្តឈាមយ៉ាងងាយដែលត្រូវ ការឈាមតែបន្តិចប៉ុណ្ណោះពីដៃ ។ វេជ្ជបណ្ឌិតមិនតែងតែធ្វើតេស្តនេះនោះទេ ដូច្នេះហើយជាការសំខាន់ដែលលោកអ្នកស្នើសុំអោយធ្វើ តេស្តនេះ ។



#### តើអ្នកណាខ្លះគួរតែធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B?

តេស្តជំងឺរលាកថ្លើមប្រភេទ B គឺត្រូវបានណែនាំអោយធ្វើសម្រាប់

- មនុស្សដែលបានកើតក្នុងប្រទេសកម្ពុជា និងប្រទេសអាស៊ីឯទៀត
- មនុស្សដែលមាតាបិតារបស់ខ្លួន មកពីប្រទេសកម្ពុជា និងប្រទេសអាស៊ីឯទៀត
- មនុស្សដែលរស់ជាមួយអ្នកដែលមាន ជំងឺរលាកថ្លើមប្រភេទ B

### តើហេតុអ្វីមនុស្សគួរតែធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B?

ការធ្វើតេស្ត អាចជួយជនម្នាក់អោយដឹងថា គេមានជំងឺរលាកថ្លើមប្រភេទ B ឬអត់ ។ មានការព្យាបាលផ្តល់ជូន សម្រាប់ជំងឺរលាកថ្លើមប្រភេទ B ដែលអាចបង្ការមិនអោយឈានទៅដល់ការខូចខាតថ្លើមធ្ងន់ធ្ងរ ។ មនុស្សដែលបានរកឃើញថាគាត់មានជំងឺរលាកថ្លើមប្រភេទ B ក៏អាចជួយរក្សាសមាជិកគ្រួសាររបស់ខ្លួនអោយមានសុខភាពល្អផងដែរ ។ នេះគឺជាមូលហេតុដែលស្ត្រីទាំងឡាយតែងតែធ្វើតេស្តរកជំងឺរលាកថ្លើមប្រភេទ B នៅពេលគាត់មានផ្ទៃពោះ ។

សមាជិកគ្រួសារដែលមិនធ្លាប់មានជំងឺរលាកថ្លើមប្រភេទ B អាចចាក់ថ្នាំបង្ការពីការកើតជំងឺនេះ ។ លទ្ធផលតេស្តជំងឺរលាកថ្លើមប្រភេទ B នឹងត្រូវរក្សារជាការសម្ងាត់ ។ មនុស្សមានជំងឺរលាកថ្លើមប្រភេទ B មិនអាចត្រូវបានគេបង្ខំអោយចេញពីសហរដ្ឋអាមេរិកនោះឡើយ ។ ពួកគេក៏មិនអាចត្រូវបានគេបញ្ឈប់ពីកន្លែងធ្វើការ ឬបង្ខំអោយចាកចេញពីសាលារៀននោះដែរ ។

### តើជំងឺរលាកថ្លើមប្រភេទ B ត្រូវបានព្យាបាលយ៉ាងដូចម្តេចដែរ ?

មនុស្សដែលមានជំងឺរលាកថ្លើមប្រភេទ B ត្រូវតែទៅជួបវេជ្ជបណ្ឌិតដែលមានចំណេះដឹងជ្រៅជ្រះអំពីជំងឺនេះ ។ វេជ្ជបណ្ឌិតអាចផ្តល់ថ្នាំដែល នឹងការពារការខូចខាតថ្លើម ។ វាជាការសំខាន់ ដែលត្រូវសួរវេជ្ជបណ្ឌិតសិន មុននឹងប្រើថ្នាំថ្លើមមកពីប៉ែកបូព៌ា ពីព្រោះវាអាចធ្វើ អោយខូចថ្លើម ឬបង្កអោយមានបញ្ហាជាមួយថ្នាំខ្លះដែលវេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា ។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

Hep B United™
ស្រឡាញ់គ្រួសាររបស់អ្នក
ចាប់ផ្តើមជាមួយនឹងការថែរក្សារខ្លួនអ្នក ។

October 2013

Khmer Publication No. 221614

# HEPATITIS B

KNOW HEPATITIS B™

## Are You At Risk?

## What is Hepatitis B?

Hepatitis B is a liver disease. It is caused by the Hepatitis B virus. For some people who get Hepatitis B, the virus stays in the body, causing a lifelong illness. Hepatitis B can cause serious health problems over time. These problems can include liver cancer and liver failure.

## How is Hepatitis B spread?

Hepatitis B is spread when someone comes in contact with blood from a person who has the disease. Most people born in Cambodia and other Asian countries who have Hepatitis B were infected as infants or young children. Hepatitis B can be passed from an infected mother to her baby at birth or from a family member to young children.

Hepatitis B is not a genetic disease. People also do not get Hepatitis B from sharing meals, bowls or utensils with someone who has the disease. Hepatitis B is not spread through breastfeeding, hugging, kissing, holding hands, coughing, or sneezing.

## How common is Hepatitis B?

Hepatitis B is very common in Cambodia and other Asian countries. Approximately 1 in 12 Asians are living with Hepatitis B, but most people do not know it.

## What are the symptoms of Hepatitis B?

Most people who have Hepatitis B do not know they have it. The disease does not always cause symptoms. Hepatitis B can stay hidden in the body. Many people can live with Hepatitis B for 20 years without feeling sick. Still, liver damage from the disease can take place during this time.

## How serious is Hepatitis B?

Hepatitis B can become very serious. For some people, this disease leads to liver damage, like liver failure or cancer.

## How do people know if they have Hepatitis B?

A Hepatitis B test lets people know if they have it. This is a simple blood test that takes only a little bit of blood from a person's arm. Doctors do not always do this test, so it is important to ask to be tested.



## Who should be tested for Hepatitis B?

Hepatitis B testing is recommended for:

- People born in Cambodia and other Asian countries
- People whose parents were born in Cambodia and other Asian countries
- People who live with someone who has Hepatitis B

## Why should people be tested for Hepatitis B?

Getting tested lets a person know if he or she has Hepatitis B. There are treatments available for Hepatitis B that can help prevent serious liver damage. People who find out they have Hepatitis B can also keep other family members healthy. This is why women are always tested for Hepatitis B when they are pregnant. Family members who have never had Hepatitis B can get a vaccine to protect them from getting it.

Hepatitis B test results will be kept confidential. People with Hepatitis B cannot be forced to leave the United States. They also cannot be fired from a job, or forced to leave school.

## How is Hepatitis B treated?

People who have Hepatitis B should see a doctor who is very knowledgeable about the disease. The doctor can give medicines that will slow down liver damage. It is important to ask the doctor before taking any Eastern liver medicines because they might hurt the liver or cause problems with some of the medicines prescribed by the doctor.

U.S. Department of Health and Human Services
Centers for Disease Control and Prevention

Hep B United™
hepbunited.org

cdc.gov/knowhepatitisB

October 2013

Publication No. 221614